ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK
ដើម្បីកសិករនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

# គម្រោងអាជីវកម្មដំណាំស្ពៃចង្កឹះ ក្នុងផ្ទះសំណាញ់



រៀបចំដោយ
គណៈកម្មការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល នៃ
ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (អេ.អ.ឌី.ប៊ី)
ខែមិថុនា ឆ្នាំ២០២៤

# មាតិកា


១-សេចក្តីផ្តើម ........ ១

២-ការអនុវត្តការដាំដុះ ........ ១

ក. ការសាងសង់ផ្ទះសំណាញ់ ........ ១

ខ. ការរៀបចំដី ........ ១

គ. ល្បាយដីបណ្តុះកូន និងការរៀបចំ ........ ២

ឃ. ការរៀបចំប្រព័ន្ធទឹក ........ ២

ង. ការជ្រើសរើសពូជ ........ ២

ច. ការបណ្តុះកូនស្ពៃចង្កឹះ ........ ៣

ឆ. វិធីដាំដុះ ........ ៣

ជ. ការថែទាំ ........ ៣

ឃ. ការដាក់ជី ........ ៣

ញ. កត្តាចង្រៃ ........ ៣

ដ. អាយុកាលដាំដុះ និងប្រមូលផល ........ ៤

ថ. និន្នាការតម្លៃ ........ ៤

៣- តម្រូវការទុនដំបូងក្នុងការដាំដុះដំណាំស្ពៃចង្កឹះ (លើផ្ទៃដីទំហំ ១,០០០ម៉ែត្រការ៉េ) ........ ៤

៤- ការវិភាគសេដ្ឋកិច្ចលើការដាំស្ពៃចង្កឹះ ........ ៤

៥-លទ្ធភាពចំណេញ ផ្អែកលើនិន្នាការតម្លៃ ........ ៥

៦-ខ្សែច្រវាក់តម្លៃ ........ ៦

៧-ហានិភ័យ ........ ៦

៨-សេចក្តីសន្និដ្ឋាន ........ ៧

# ដំណាំស្ពៃចង្កឹះក្នុងផ្ទះសំណាញ់

## ១-សេចក្តីផ្តើម

ស្ពៃចង្កឹះជាបន្លែមួយប្រភេទក្នុងចំណោមបន្លែស្លឹកជាច្រើនដែលកសិករយើងនិយមចូលចិត្តដាំ ព្រោះវាជាបន្លែដែលអាចយកមកប្រើប្រាស់ក្នុងការធ្វើម្ហូបអាហារបានច្រើនមុខ។ កាលពីមុនកសិករច្រើនដាំនៅក្នុងសួនបន្លែតូចៗជាលក្ខណៈគ្រួសារ។ ប៉ុន្តែ ដោយសារបច្ចុប្បន្នស្ពៃចង្កឹះបានក្លាយជាប្រភេទបន្លែដែលពេញនិយម មានតម្រូវការនៅលើទីផ្សារច្រើន បានធ្វើឱ្យកសិករដាំដុះបន្លែនេះកាន់តែច្រើនឡើង។ ស្ពៃចង្កឹះអាចលូតលាស់បានស្ទើរគ្រប់រដូវ ប៉ុន្តែកសិករនិយមដាំនៅរដូវត្រជាក់ព្រោះវាលូតលាស់បានល្អជាងការដាំនៅរដូវក្តៅ ហើយក៏ពុំសូវមានសត្វល្អិតចង្រៃស៊ីបំផ្លាញទៀតផង។ ដោយសារកក្តាអាកាសធាតុភ្លៀងជ្រុំ ឬក្តៅពេក ការដាំបន្លែនៅទីវាលឬក្រៅផ្ទះសំណាញ់គឺបានជាមធ្យមចន្លោះពី២-៣ដងប៉ុណ្ណោះក្នុងមួយឆ្នាំ និងចំណាយខ្ពស់លើធាតុចូលកសិកម្ម ទទួលបានទិន្នផលទាបជាងការដាំក្នុងផ្ទះសំណាញ់ ហើយគុណភាពក៏អន់ជាងបន្លែដែលដាំក្នុងផ្ទះសំណាញ់ដែរ។ ការដាំបន្លែក្នុងផ្ទះសំណាញ់គឺទទួលបានផលខ្ពស់ ចំណាយតិច មានទីផ្សារល្អ ដោយសារមានការនិយមពីអ្នកបរិភោគ។ ការដាំបន្លែក្នុងផ្ទះសំណាញ់អាចជួយលើកកម្ពស់ជីវភាពកសិករ សុខភាព បរិស្ថាន និងកាត់បន្ថយការចំណាយលើថ្នាំ និងជីកសិកម្មបានមួយចំនួនធំ។ ការដាំបន្លែនៅក្នុងផ្ទះសំណាញ់ កសិករអាចធ្វើការដាំដុះបាននៅគ្រប់រដូវកាលជាប្រចាំពេញមួយឆ្នាំ ព្រោះផ្ទះសំណាញ់ជួយការពារដំណាំពីការយាយីរបស់សត្វល្អិតចង្រៃ ម្យ៉ាងទៀតផ្ទះសំណាញ់បានផ្តល់នូវលក្ខខណ្ឌអាកាសធាតុសមស្របមួយដែលអាចឱ្យបន្លែលូតលាស់បានទាំងរដូវវស្សា និងរដូវប្រាំង។

## ២-ការអនុវត្តការដាំដុះ

**ក. ការសាងសង់ផ្ទះសំណាញ់÷** ទំហំផ្ទះសំណាញ់គឺប្រែប្រួលទៅតាមសណ្ឋានដី និងបរិមាណតម្រូវការបន្លែរបស់ទីផ្សារ ដោយរួមបញ្ចូលទាំងការប្រើប្រាស់ប្រព័ន្ធទឹកស្រោចស្រព។





**ខ. ការរៀបចំដី៖** ភ្ជួរដីឱ្យម៉ដ្ឋល្អពី ២ ទៅ ៣សារ រួចហាលដីទុករយៈពេលពី ១០ ទៅ ១៥ថ្ងៃ។ សម្រាប់រដូវវស្សាអាចធ្វើជារង ដែលមានទទឹងរងពីខាងលើ ១.៤ម៉ែត្រ និងបាតរង ១.៥ម៉ែត្រ កម្ពស់រងចាប់ពី ០.១០ ទៅ ០.១៥ម៉ែត្រ និងរដូវប្រាំងពុំចាំបាច់ធ្វើរងក៏បាន។ កសិករត្រូវរៀបទុយោតំណក់ដាក់លើរងចំនួន ៧ជួរក្នុងមួយរង ដោយត្រូវទុកចន្លោះរង ០.៤ម៉ែត្រ ធ្វើឱ្យក្នុងផ្ទះសំណាញ់ពុំមានទឹកដក់ ដែលនាំឱ្យប៉ះពាល់ដល់ការដុះលូតលាស់ និងទិន្នផលស្ពៃឡើយ។ ត្រូវប្រើប្រាស់ជីធម្មជាតិទ្រាប់បាតក្នុងបរិមាណ ១,០០០ទៅ ២,០០០គីឡូក្រាម លើផ្ទៃដី ១០០០ម៉ែត្រការ៉េ តាមរងដំណាំ ។

**គ. ល្បាយដីបណ្តុះកូន៖** ល្បាយដីបណ្តុះកូនស្ពៃចង្កឹះរួមមាន ដីដំបូក/ដីទន្លេ ឬដីស្រទាប់លើដែលមានជីជាតិ ១ធុង លាយជាមួយធ្យូងអង្កាម ២ធុង និងកំប៉ុស ២ធុង ច្របល់ចូលគ្នា លីង ឬចំហុយសម្លាប់មេរោគ និងគ្រាប់ស្មៅចង្រៃ។ បន្ថែមមេផ្សិតត្រៃកូឌឺម៉ា (Trichoderma) ១គីឡូក្រាម សម្រាប់ល្បាយដី បណ្តុះ១តោន ដើម្បីសម្លាប់ផ្សិតចង្រៃ។

**ឃ. ការរៀបចំប្រព័ន្ធទឹក៖** ប្រើប្រាស់ប្រព័ន្ធដំណក់ទឹក(ទ្រីប)គឺសមស្របសម្រាប់ដំណាំស្ពៃចង្កឹះដែលដាំដុះក្នុងផ្ទះសំណាញ់ តែបើដាំដុះលើទីវាលប្រព័ន្ធទឹកសាចល្អប្រសើរជាង ចំណាយតិចជាង និងប្រសិទ្ធភាពជាងប្រព័ន្ធតំណក់ទឹក។

**ង. ការជ្រើសរើសពូជ៖** ត្រូវការស្គាល់ពូជឱ្យបានច្បាស់លាស់មុនធ្វើការដាំដុះ គ្រាប់ពូជដែលត្រូវជ្រើសរើសយកមកដាំត្រូវមានលក្ខណៈដូចខាងក្រោម៖

- ដុះលូតលាស់សមស្របនឹងតំបន់ផលិត ហើយមិនប្រកាន់រដូវ
- ផ្តល់ទិន្នផលខ្ពស់ រយៈពេលលូតលាស់ខ្លី
- ពេញនិយម និងមានតម្រូវការទីផ្សារ
- ធន់ទ្រាំនឹងជំងឺ និងសត្វល្អិតបំផ្លាញ
- គ្រាប់ពូជសុទ្ធគ្មានជំងឺ សត្វល្អិតបំផ្លាញ ភាគរយដំណុះខ្ពស់

**ពូជមួយចំនួនដែលកសិករជ្រើសរើសសម្រាប់ការដាំដុះ៖**










- ពូជ ស្ពៃចង្កឹះ CAI SIM 34 OP ជាផលិតផលរបស់ក្រុមហ៊ុន វ៉ាហាយ (VAHAY)
- ពូជ ចាក់អង្រែ ១ ជាផលិតផលរបស់ក្រុមហ៊ុន ខ្មែរស៊ីត (Khmer Seed)

- ពូជ ឡុងលីវ ជាផលិតផលរបស់ក្រុមហ៊ុន អេសខេ អេហ្គ្រី ស៊ីត (SK Agri Seed)
- ពូជ អូនី ONI ជាផលិតផលរបស់ក្រុមហ៊ុន East West Seed (ព្រួញក្រហម)
- ពូជស្ពៃចង្កឹះ CS020 ជាផលិតផលរបស់ក្រុមហ៊ុនម៉ាលីសានគ្រុប (MSG)

**ច. ការបណ្ដុះកូនស្ពៃចង្កឹះ÷** កសិករត្រូវការសម្ភារៈចាំបាច់មួយចំនួនរួមមាន ថាសបណ្ដុះកូន(២០០រន្ធ) ដីបណ្ដុះ ធុងបាញ់ទឹក និងគ្រាប់ពូជស្ពៃដែលមានគុណភាព។ ជាដំបូងត្រូវដាក់ដីចូលក្នុងថាសបណ្ដុះ ដោយដាក់គ្រាប់ស្ពៃចំនួន ១គ្រាប់ក្នុងមួយរន្ធថាសបណ្ដុះ បន្ទាប់មករោយដីស្តើងៗពីលើ និងធ្វើការបាញ់ទឹកស្រោច។ ការបណ្ដុះគួរធ្វើក្នុងរោងបណ្ដុះ ឬក្នុងផ្ទះសំណាញ់។ កូនស្ពៃដុះលូតលាស់បាន ២សប្ដាហ៍ ទើបយកទៅដាំក្នុងផ្ទះសំណាញ់។

**ឆ. វិធីដាំដុះ÷** ក្រោយការដុះលូតលាស់បានប្រមាណជា ២សប្ដាហ៍ កសិករអាចយកកូនស្ពៃចង្កឹះទៅដាំក្នុងរង ដោយជ្រើសរើសកូនស្ពៃធំៗ និងកូនតូចៗដាក់ដាំក្នុងរងដាច់ដោយឡែកពីគ្នា ដើម្បីកូនដំណាំអាចលូតលាស់បានស្មើគ្នា មិនប្រជែងការទទួលពន្លឺ ទឹកនិងការស្រូបយកជីជាតិ។ ស្ពៃចង្កឹះអាចដាំចន្លោះគុម្ព និងចម្លោះជួរ ពី ១៥ ទៅ ២០ស.ម ហើយមួយរងដាំបាន ៥ ទៅ ៧ជួរ។

**ជ. ការថែទាំ÷** ត្រូវស្រោចទឹកក្នុងមួយថ្ងៃ២ដង គឺនៅពេលព្រឹកម្ដង និងពេលរសៀលម្ដង ផ្ដែកលើសំណើមដី និងមិនគួរស្រោចស្រពនៅពេលល្ងាចចាប់ពីម៉ោង៥ទៅឡើយ ព្រោះអាចបង្កឱ្យកើតជំងឺផ្សិតលើដំណាំស្ពៃ។ ក្រោយដាំបាន ១សប្ដាហ៍ កសិករអាចធ្វើការជ្រោយដីតាមគល់ស្ពៃចង្កឹះ និងដកស្មៅចង្រៃចេញពីរងដំណាំ ដើម្បីរួមចំណែកក្នុងការគ្រប់គ្រងកត្តាចង្រៃ និងការដណ្ដើមយកជីជាតិដី។

**ឈ. ការដាក់ជី÷** ក្រោយការដាំដុះរួចរាល់ត្រូវមានកម្មវិធីប្រើប្រាស់ជីសម្រាប់ដំណាំស្ពៃចង្កឹះ កសិករអាចប្រើប្រាស់ប្រភេទជីទឹកនៅដំណាក់កាលលូតលាស់ដោយបញ្ចូលតាមប្រព័ន្ធដំណក់ទឹក និងការបាញ់បន្ថែមទៅលើស្លឹក។ ជីគោលជាចម្បងៗគឺមានសារធាតុ N P និង K ដែលជាតម្រូវការចាំបាច់សម្រាប់ការលូតលាស់ និងភាពធន់របស់ស្ពៃចង្កឹះ។ តាមការបញ្ជាក់ពីកសិករ ដោយសារមានការប្រើប្រាស់ជីទ្រាប់បាតច្រើននៅដំណាក់កាលការរៀបចំដី កសិករបានបន្ថយនៅការប្រើប្រាស់ជីគីមីសម្រាប់ការដាំដុះ អាស្រ័យលើស្ថានភាពនៃការការលូតលាស់របស់ដំណាំ ជាក់ស្ដែងកសិករបានប្រើប្រាស់ជី ដេ អា ប៉េ ចំនួន ៥គីឡូក្រាម និងជីកាលី ៥គីឡូក្រាមសម្រាប់ផ្ទះសំណាញ់ដែលមានទំហំ ១,០០០ ម៉ែត្រការ៉េ ដោយដាក់១-២ ដង ក្រោយការដាំដុះបាន១សប្ដាហ៍ ឬ១០ថ្ងៃ។

**ញ. កត្តាចង្រៃ÷** ជាទូទៅកសិករតែងជួបប្រទះជាញឹកញាប់នូវកត្តាចង្រៃដែលបំផ្លាញ ដំណាំស្ពៃចង្កឹះ មានដូចជា ÷ ដង្កូវយោលទោង ដង្កូវកាត់ដើម ទាកគូ ចៃ ជំងឺផ្សិត។

   

   

**ដ.អាយុកាលដាំដុះ និងប្រមូលផល÷** ស្ពៃចង្កឹះជាដំណាំមានអាយុកាលខ្លី ២០-២៥ ថ្ងៃក្រោយការដាំកសិករអាចប្រមូលផលបាន បើគិតពីថ្ងៃបណ្ដុះកូនរហូតដល់ពេលប្រមូលផលគឺមានរយៈពេលប្រមាណ ៣០-៤០ថ្ងៃ ដែលអាចទទួលផលជាមធ្យមចំនួន៣,០០០គីឡូក្រាម/ផ្ទះសំណាញ់ទំហំ ១,០០០ ម៉ែត្រការ៉េ។ ការប្រមូលផលកសិករត្រូវប្រើប្រាស់កូនកាំបិតកាត់ត្រឹមគល់ ហើយដាក់សំដិលបន្តិចទើបច្រកចូលក្នុងថង់ ឬកាតារ ដើម្បីដឹកជញ្ជូនទៅទីផ្សារ ឬផ្តល់ជូនអតិថិជន។

**ថ.និន្នាការតម្លៃ÷** ស្ពៃចង្កឹះអាចទទួលបានតម្លៃល្អនៅរដូវភ្លៀង ព្រោះពិបាកដាំដុះ ភ្លៀងជោគជាំពិបាកថែទាំ ម្យ៉ាងការផ្គត់ផ្គង់ស្ពៃចង្កឹះពីការដាំដុះក្នុងផ្ទះសំណាញ់នៅមានបរិមាណតិចតួចនៅឡើយ។

**៣-តម្រូវការទុនដំបូងក្នុងការដាំដុះដំណាំស្ពៃចង្កឹះ (លើផ្ទៃដីទំហំ ១,០០០ម៉ែត្រការ៉េ)**

| បរិយាយ | ចំនួនទឹកប្រាក់ (រៀល) |
|---|---|
| ចំណាយលើការដាំដុះ | 1,521,000 |
| ចំណាយលើប្រព័ន្ធស្រោចស្រព | 12,000,000 |
| ផ្ទះសំណាញ់ និងសម្ភារៈផ្សេងៗ | 64,860,000 |
| **សរុប** | **78,381,000** |

## ៤-ការវិភាគសេដ្ឋកិច្ចលើការដាំស្ពៃចង្កឹះក្នុងផ្ទះសំណាញ់ (លើផ្ទៃដីទំហំ ១,០០០ម៉ែត្រការ៉េ)

រយៈពេលដាំដុះ ៣៥ថ្ងៃ / វដ្ត (ការដាំដុះនៅសង្កាត់ចម្រើនផល ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់)

| បរិយាយ | ឯកត្តា | ចំនួនឯកត្តា | តម្លៃ (៛) ១ឯកត្តា | ទឹកប្រាក់សរុប (រៀល) | ចំនួនសាររំលស់ | ទឹកប្រាក់សរុប |
|---|---|---|---|---|---|---|
| **១-ចំណូលសរុបពីការលក់ស្ពៃចង្កឹះ** | | | | | | **9,000,000** |
| ចំណូលពីការលក់ស្ពៃចង្កឹះ | គ.ក | 3,600 | 2,500 | 9,000,000 | | 9,000,000 |
| **២-ចំណាយសរុប** = ចំណាយប្រែប្រួល + ចំណាយមិនប្រែប្រួល/ថេរ | | | | | | **2,689,750** |
| ២.ក. ចំណាយប្រែប្រួល | | | | 1,521,000 | | 1,521,000 |
| ពូជ | កញ្ចប់ | 6 | 6,000 | 36,000 | | 36,000 |
| ជីលាមកសត្វ/កំប៉ុស | គ.ក | 2,000 | 500 | 1,000,000 | | 1,000,000 |
| ជីដេអាប៉េ និងកាលី | គ.ក | 10 | 2,500 | 25,000 | | 25,000 |
| ថ្នាំសម្លាប់សត្វល្អិត+ជំងឺ | ឈុត | 2 | 50,000 | 100,000 | | 100,000 |
| ថ្លៃកម្មករដាំ និងថែទាំ | នាក់/ដង | 8 | 30,000 | 240,000 | | 240,000 |
| ប្រេងឥន្ធនៈ | លីត្រ | 30 | 4,000 | 120,000 | | 120,000 |
| ២.ខ. ចំណាយមិនប្រែប្រួល/ថេរ (រំលោះ ៨វដ្ត/ឆ្នាំ) | | | | 76,860,000 | | 1,168,750 |
| ផ្ទះសំណាញ់(ប្រើ១០ឆ្នាំ) | ផ្ទះ | 1 | 61,500,000 | 61,500,000 | 80 | 768,750 |
| ស្នប់បូមទឹក (ប្រើ៥ឆ្នាំ) | គ្រឿង | 1 | 4,000,000 | 4,000,000 | 40 | 100,000 |
| ម៉ាស៊ីនវាយដី (ប្រើ៥ឆ្នាំ) | គ្រឿង | 1 | 2,400,000 | 2,400,000 | 40 | 60,000 |
| ប្រព័ន្ធទឹក (ប្រើ២ឆ្នាំ) | ឈុត | 1 | 2,000,000 | 2,000,000 | 16 | 125,000 |
| ធុងបាញ់ថ្នាំ ២០លីត្រ (៣ឆ្នាំ) | ឈុត | 1 | 160,000 | 160,000 | 24 | 6,667 |
| អណ្ដូងបុក (ប្រើ១០ឆ្នាំ) | ឈុត | 1 | 6,000,000 | 6,000,000 | 80 | 75,000 |
| ស្បៃពណិខៀវ(ប្រើ៣ឆ្នាំ) | ដុំ | 4 | 200,000 | 800,000 | 24 | 33,333 |
| ៣-ចំណេញសរុប | | | | | | 6,310,250 |
| **ថ្លៃដើម/គ.ក** = ចំណាយសរុប/ទិន្នផល | | | | | | **747** |
| ចំណេញ/គ.ក = ចំណេញសរុប/ទិន្នផល | | | | | | 1,753 |

**៥-លទ្ធភាពចំណេញផ្អែកលើនិន្នាការតម្លៃ ÷** ដាំស្ពៃចង្កឹះក្នុងផ្ទះសំណាញ់លើផ្ទៃដី ១,០០០ម៉ែត្រការ៉េ

-តម្លៃទាបបំផុត ១,០០០៛/គ.ក និងតម្លៃខ្ពស់បំផុត ៤,៥០០៛/គ.ក

| ករណី | តម្លៃ ជារៀល | ទិន្នផល (គ.ក) | ចំណូល ជារៀល | ចំណាយ សរុប(រៀល) | ចំណេញ | |
|---|---|---|---|---|---|---|
| | | | | | ជារៀល | % |
| *ករណីទី១* | 1,000 | 3,600 | 3,600,000 | 2,689,750 | 910,250 | 34% |
| *ករណីទី២* | 1,500 | 3,600 | 5,400,000 | 2,689,750 | 2,710,250 | 101% |
| *ករណីទី៣* | 2,000 | 3,600 | 7,200,000 | 2,689,750 | 4,510,250 | 168% |
| *ករណីទី៤* | 2,500 | 3,600 | 9,000,000 | 2,689,750 | 6,310,250 | 235% |
| *ករណីទី៥* | 3,000 | 3,600 | 10,800,000 | 2,689,750 | 8,110,250 | 302% |
| *ករណីទី៦* | 3,500 | 3,600 | 12,600,000 | 2,689,750 | 9,910,250 | 368% |
| *ករណីទី៧* | 4,000 | 3,600 | 14,400,000 | 2,689,750 | 11,710,250 | 435% |
| *ករណីទី៨* | 4,500 | 3,600 | 16,200,000 | 2,689,750 | 13,510,250 | 502% |

**៦-ខ្សែច្រវាក់តម្លៃ÷**

កសិករ÷ លក់ចេញ២,៥០០៛/គ.ក - ថ្លៃដើម ៧៤៧៛/គ.ក = ចំណេញ ១,៧៥៣៛/គ.ក

ឈ្មួញកណ្ដាល÷ បោះដុំ ៣,៥០០៛/គ.ក(ថ្លៃដឹកជញ្ជូន ៥០០៛/គ.ក) ចំណេញ ៥០០៛/គ.ក

អ្នកលក់រាយ÷ លក់៤,៥០០៛/គ.ក(ជួលតូប និងខូចខាត៥០០៛/គ.ក) ចំណេញ ៥០០៛/គ.ក

**៧-ហានិភ័យ ÷**

តាមរយៈនៃការចុះសិក្សាផ្ទាល់ពីកសិករដាំដុះស្ពៃចង្កឹះនៅសង្កាត់ចម្រើនផល ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ មានហានិភ័យមួយចំនួនអាចកើតឡើងជាយថាហេតុលើដំណើរការដាំដុះដូចជា÷

| ល.រ | ប្រភេទ ហានិភ័យ | ពិពណ៌នាហានិភ័យ | វិធានការ |
|---|---|---|---|
| ១ | **ហានិភ័យ ផលិតកម្ម** | ទិន្នផលធ្លាក់ចុះ បណ្ដាលមកពីកត្តា<br>- ជំងឺផ្សិត<br>- សត្វល្អិត | - គួរប្រើប្រាស់វិធានការការពារ ដំណាំ និងមានកាលវិភាគប្រើប្រាស់ថ្នាំសម្រាប់សត្វល្អិត និងជំងឺឱ្យបានត្រឹមត្រូវ |

| | | | |
|---|---|---|---|
| | | - អាកាសធាតុ | -ប្រើប្រាស់ថ្នាំកសិកម្ម (ជីវសាស្ត្រ) តាមនិយាមកំណត់លើដីមុននឹងដាំដុះដំណាំនៅវគ្គថ្មី<br>-ជ្រើសរើសពូជដែលធន់នឹងកត្តាចង្រៃនានា (សត្វល្អិត ជំងឺ និងអាកាសធាតុ)<br>-សិក្សាបន្ថែមពីបច្ចេកទេសដាំដុះសមស្របក្នុងតំបន់ |
| ២ | **ហានិភ័យទីផ្សារ** | -មានតម្រូវការប្រភេទស្លែចង្កឹះផ្សេងៗគ្នា÷ អតិថិជនខ្លះត្រូវការដើមតូច ខ្លះត្រូវការដើមធំ<br>-ការធ្លាក់ចុះតម្លៃដោយសារមានការដាំដុះច្រើនគ្នា | -ពង្រីកបណ្តាញទីផ្សារឱ្យបានច្រើនដើម្បីកាត់បន្ថយការពឹងផ្អែកលើទីផ្សារក្នុងតំបន់តែមួយ<br>-ចងក្រងក្រុមអ្នកផលិត ដើម្បីធ្វើកិច្ចសន្យាទិញ- លក់ និងធ្វើផែនការផលិតតាមកិច្ចសន្យា<br>-ផលិតឱ្យបានទាំងបរិមាណ និងគុណភាព<br>-ធ្វើការស្រាវជ្រាវព័ត៌មានទីផ្សារ ជាប្រចាំ |

**៨-សេចក្តីសន្និដ្ឋាន**

ការដាំដុះបន្លែស្លែចង្កឹះនេះ មិនត្រឹមតែជាបន្លែផ្គត់ផ្គង់តម្រូវការបរិភោគប្រចាំថ្ងៃបានប៉ុណ្ណោះទេ តែជាមុខរបរជាប្រចាំរបស់កសិករអាចជួយបង្កើនប្រាក់ចំណូលគ្រួសារបានមួយកម្រិតថែមទៀត ។ មុនពេលដាំដុះ កសិករត្រូវចេះជ្រើសរើសគ្រាប់ពូជណាដែលមានភាពធន់ទៅនឹងការបំផ្លាញពីសត្វល្អិតចង្រៃ ជាពិសេសភាពធន់នឹងការប្រែប្រួលអាកាសធាតុ។ ដំណាំស្លែចង្កឹះគឺជាដំណាំងាយស្រួលថែទាំ មានអាយុកាលខ្លី មិនសូវខ្វះទីផ្សារនោះទេ ព្រោះមានឈ្មួញមកទទួលទិញដល់ចម្ការ ដើម្បីលក់ចែកចាយទៅទីផ្សារក្នុងស្រុក និងនៅផ្សារទំនើបក្នុងទីក្រុងភ្នំពេញ និងតាមបណ្តាខេត្តនានា ដោយលក់ក្នុងតម្លៃបោះដុំចន្លោះពី ១,០០០៛ ទៅ៤,៥០០៛/គ.ក ជាតម្លៃដែលកសិករមានលទ្ធភាពចំណេញ។

**ប្រភពនៃការសិក្សាស្រាវជ្រាវ÷**

-កសិករដាំដុះស្លែចង្កឹះក្នុងផ្ទះសំណាញ់ នៅសង្កាត់ចម្រើនផល ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់

-ឯកសារបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ